**សកម្មភាព** ៖ **ល្បែងពិសោធកងផ្សេង**

**ចិត្តចលភាព** ៖ បំណិនចលនាតូច៖ ការហ្វឹកហាត់បង្កើនកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃ និងសាច់ដុំភ្នែក

**វិទ្យាសាស្ត្រ** ៖ ការរស់នៅប្រចាំថ្ងៃ៖ ការស្វែងយល់និងការសង្កេត៖

**គោលបំណង**

**ចិត្តចលភាព** ៖ បំណិនសម្បទា៖ កំណត់ចំណុចគោលដៅនៃចលនាដៃដោយការទប់លំនឹង និងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយឬលេងល្បែងបានរឹងមាំល្អ។

**វិទ្យាសាស្ត្រ** ៖ វិជ្ជាសម្បទា៖ ពិសោធន៍និងស្វែងយល់ដោយប្រើប្រាស់សម្ភារផ្សេងៗនៅក្នុងការលេងដូចជា៖ លិច អណ្តែត ជ្រាបទឹក និងមិនជ្រាបទឹក វត្ថុរលាយនិងមិនរលាយ ការលាយពណ៌ បណ្តុះគ្រាប់ធញ្ញជាតិ ខ្យល់ជាដើម...។

**កម្រិតសិក្សា** ៖ មធ្យមនិងខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ មានធូប ដែកកេះ ដបជ័រធំឬតូច

**ការរៀបចំ** ៖ ត្រៀមសម្ភារដែលត្រៀមនឹងពិសោធន៍ឱ្យបានរួចរាល់ ជៀសវាងភ្លេចសម្ភារណាមួយ។

**សេចក្តីណែនាំ** ៖

1. ល្បែងសកម្មភាពនេះ និយាយពីការពិសោធន៍មួយដែលកូនៗគួរដឹង
2. សួរកុមារសំណួរខ្លះៗដែលទាក់ទងទៅនឹងការពិសោធន៍នេះផង
3. គ្រូប្រាប់ឬបង្ហាញពីសកម្មភាពពិសោធន៍នេះទៅកាន់កុមារជាមុនសិន បន្ទាប់មកឱ្យកុមារលេងសាក់ល្បងក៏បាន។
    - ដំបូង ដុតធូបឱ្យឆេះជាមុនសិន



- ❖ បន្ទាប់មក ធូបដែលដុតរួចនោះ ត្រូវពន្លត់វាកុំឱ្យមានអណ្តាតភ្លើង ហើយស៊កវាទៅក្នុងដបជ័រនោះ ទុកឱ្យវាមានផ្សែងឱ្យពេញដបសិន



- ❖ ចុងក្រោយ យើងគ្រាន់តែដកធូបនោះមកក្រៅវិញ
ហើយចាប់ផ្តើមច្របាច់ដបនោះហើយព្រលែងវាវិញលឿនៗ
ដើម្បីឱ្យផ្សែងក្នុងដបចេញតាមមាត់ដបទៅជាកងផ្សែងបានស្អាតផងដែរ។



- ❖ ហេតុអ្វីបានជាផ្សែងចេញមកក្រៅជារង្វង់បែបនេះ? សូមមើលការប្រាប់ខាងក្រោម៖

